ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខ: ២១៥ សន៤៧ /គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៣

**សូមគោរពជូន**

**ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត**

**ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ**

**កម្មវត្ថុ** ៖ ការជ្រើសរើសជំនួយការបច្ចេកទេសឃុំ សង្កាត់(CTA) ដែលគាំទ្រដោយគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប ។

**យោង** ៖ កិច្ចព្រមព្រៀងហិរញ្ញប្បទានលេខ 2599 និង 0186-CARM(SF) ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៩ រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ។

-ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៣ ។

**ជូនភ្ជាប់** ៖ សេចក្តីណែនាំស្តីពីការជ្រើសរើសជំនួយការបច្ចេកទេសឃុំ សង្កាត់ ។

តបតាមកម្មវត្ថុ និងយោងខាងលើ សូមជម្រាបជូនឯកឧត្តមអភិបាលខេត្តមេត្តាជ្រាបថា គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប (TS-PRSDP) បានពង្រីកការអនុវត្តសកម្មភាពក្នុងដំណាក់កាលទី២ ចំនួន៨៨ឃុំ សង្កាត់បន្ថែមទៀត នៅក្នុងខេត្តគោលដៅបួនរួមមាន ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តបន្ទាយមាន ជ័យ។ គម្រោងមានសមាសភាគបី៖ ១) **ការអភិវឌ្ឍ ឃុំ សង្កាត់ តាមរយៈមូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់** ២) **ការបង្កើតឡើងនូវបរិយាកាសអំណោយផលសម្រាប់ជួយបង្កើនផលិតភាពកសិកម្ម និងពិពិធកម្មកសិកម្ម** និង ៣) **ការគ្រប់គ្រងគម្រោងប្រកបដោយប្រសិទ្ធភាព** ។

តាមផែនការសកម្មភាព និងថវិកាឆ្នាំ២០១៣ ការអនុវត្តសមាសភាគទី១ស្តីពីគម្រោងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់គាំទ្រដល់ការបង្កើនផលិតភាពកសិកម្ម គឺតម្រូវឱ្យមានការជ្រើសរើសជំនួយការបច្ចេកទេសឃុំ សង្កាត់ បន្ថែមសម្រាប់ជួយក្នុងការសិក្សាគម្រោង រៀបចំប្លង់បច្ចេកទេស និងត្រួតពិនិត្យការអនុវត្តគម្រោង ។ ក្នុងន័យនេះ ដើម្បីឱ្យការជ្រើសរើសបានតាមផែនការ និងស្របតាមនីតិវិធីលទ្ធកម្មដែលមានចែងក្នុងសេចក្តីណែនាំស្តីពីការជ្រើសរើសជំនួយការបច្ចេកទេសឃុំ សង្កាត់នោះ សូមឯកឧត្តមណែនាំដល់ក្រុមការងារគម្រោងថ្នាក់ខេត្ត ធ្វើការជ្រើសរើសជំនួយការបច្ចេកទេសឱ្យបានទាន់ពេលវេលា ប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាជ្រាប និងចាត់វិធានការអនុវត្តតាមការគួរ ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

ជ. **ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**ចាន់ ដារ៉ែន**

មហាវិថីព្រះនរោត្តម: លេខាធិការដ្ឋាននៃគ.ជ.អ.ប ក្រសួងមហាផ្ទៃ ។ ទូរស័ព្ទ: (៨៥៥-២៣) ៧២០ ០៦១ / ៧២០ ០៣៨ E-mail: info@ncdd.gov.kh Website: www.ncdd.gov.kh
Norodom Blvd., National Committee for Sub-National Democratic Development Secretariat (NCDDS). Ministry of Interior. Tel: (855-23) 720 061 / 720 038